ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៥៥២ សហវ.

រាជធានីភ្នំពេញ ថ្ងៃ២៦ ខែតុលា ឆ្នាំ២០១១

គោរពជូន

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម**

**កម្មវត្ថុ:** ករណីសំណើសុំថវិកាចំនួន ៣ ៩៤០ ០០០ ០០០៛ សម្រាប់ទិញប្រេងឥន្ធនៈដើម្បីដំណើរការជួសជុលស្តារប្រព័ន្ធធារាសាស្ត្រលើប្រឡាយមេ និងប្រឡាយរងតាមបណ្តាខេត្តចំនួន ២៣ ។

**យោង:** - លិខិតលេខ១៤៣៧ធទឧ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១១ របស់ក្រសួងធនធានទឹក និងឧតុនិយម

- ស្មារតីអង្គប្រជុំគណៈកម្មការអន្តរក្រសួងនាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ស្តីពីការកំណត់គោលការណ៍ និង អាទិភាព (ជំហានទី១) នៃការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលរងការខូចខាតដោយសារទឹកជំនន់ឆ្នាំ២០១១ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកភាពក្នុងការផ្តល់បុរេប្រទានថវិកាចំនួន ៣ ៩៤០ ០០០ ០០០៛ (បីពាន់ ប្រាំបួនរយសែសិបលានរៀល) សម្រាប់ទិញប្រេងឥន្ធនៈដើម្បីដំណើរការជួសជុលស្តារប្រព័ន្ធធារាសាស្ត្រលើប្រឡាយមេ និង ប្រឡាយរងតាមបណ្តាខេត្តចំនួន ២៣ ខេត្ត ដែលជាការងារមានលក្ខណៈបន្ទាន់ និងចាំបាច់ ។

មុខចំណាយនេះ ក្រសួងធនធានទឹក និង ឧតុនិយម ត្រូវរៀបចំសក្ខីប័ត្រសម្រាប់ទូទាត់តាមនីតិវិធីហិរញ្ញវត្ថុជាធរមាន មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យបានទាន់ពេលវេលា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបនិងចាត់ចែងតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ
- នាយកដ្ឋានថវិកា
- នាយកដ្ឋានហិរញ្ញកិច្ច

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com